**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៥៦ អនក្រ-បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសំរួលខ្លឹមសារនៃការបង្កើតនាយកដ្ឋានចំណុះលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ដឹកនាំ បញ្ហាការប្រយុទ្ធ ប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ.០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៨/១៧២ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម ។
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានចំណុះលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិដឹកនាំបញ្ហាការប្រយុទ្ធ ប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម ។
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិដឹកនាំ បញ្ហាការប្រយុទ្ធ ប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម ។

## សម្រេច

**មាត្រា ១:** ត្រូវបានកែសំរួលមាត្រា ១២ នៃជំពូកទី ៤ របស់អនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានចំណុះលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិដឹកនាំបញ្ហាការប្រយុទ្ធ ប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម ដូចតទៅ:

**មាត្រា ១២ ថ្មី:** -

ប្រធាននាយកដ្ឋានពិសេស គឺជាអនុប្រធានប្រចាំការមួយរូបនៃលេខាធិការដ្ឋាន គជបភ -ហើយក៏ជាមេបញ្ជាការនៃបញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម នៃ គជបភ។

បញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្មនៃ គជបភ មានមេបញ្ជាការមួយរូប មេបញ្ជាការរងមួយចំនួនតាមការចាំបាច់ និងមានសេនាធិការ និងផ្នែកភស្តុភារ និងផ្នែកនានាសំរាប់ជួយការងារដល់មេបញ្ជាការ។

មេបញ្ជាការ និងមេបញ្ជាការរង នៃបញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម នៃ គជបភ ត្រូវតែងតាំងដោយអនុក្រឹត្យ ឬ ព្រះរាជក្រឹត្យតាមសំណើរបស់ប្រធាន គជបភ ហើយមានឋានន្តរស័ក្តិចាប់ពីវរសេនីយ៍ឯកឡើងទៅសំរាប់មេបញ្ជាការ និងឋានន្តរស័ក្តិចាប់ពីវរសេនីយ៍ទោឡើងទៅសំរាប់មេបញ្ជាការរង ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មាធិការជាតិដឹកនាំ បញ្ជាការប្រយុទ្ធ ប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន គជបភ លេខាធិការដ្ឋាន គជបភ និងគ្រប់អង្គភាពពាក់ពន្ធ័ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ~~២១~~ ខែ វិច្ឆិកា ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ